# តើអ្នកអាចរកឃើញសាសនាពិតយ៉ាងដូចម្ដេច ?

*តើសាសនាទាំងអស់សុទ្ធតែផ្គាប់ព្រះហឫទ័យនៃព្រះ ឬក៏មានតែសាសនាមួយប៉ុណ្ណោះ? (១)*

*ហេតុអ្វីក៏មានសាសនាច្រើនម្ល៉េះដែលអះអាងថាជាសាសនាគ្រីស្ទាន? (២)*

*តើអ្នកអាចសម្គាល់គ្រីស្ទានពិតយ៉ាងដូចម្ដេច? (៣-៧)*



១. ព្រះយេស៊ូបានចាប់ផ្ដើមបង្កើតសាសនាគ្រីស្ទានពិតមួយ ។ ដូច្នេះ សព្វថ្ងៃនេះត្រូវមានតែមនុស្សមួយពួកឬមួយក្រុមប៉ុណ្ណោះ ដែលជាអ្នកថ្វាយបង្គំពិតដល់ព្រះយេហូវ៉ា ។ (យ៉ូហាន ៤:២៣, ២៤; អេភេសូរ ៤:៤, ៥) ព្រះគម្ពីរបង្រៀនថាមានមនុស្សចំនួនតិចតួចប៉ុណ្ណោះដែលដើរលើផ្លូវចង្អៀតទៅកាន់ជីវិត ។—ម៉ាថាយ ៧:១៣, ១៤

២. ព្រះគម្ពីរបានទាយថា ក្រោយពេលពួកសាវ័កបានទទួលមរណភាពទៅ នោះសេចក្ដីបង្រៀនមិនពិតនិងការប្រព្រឹត្តខុសផ្ទុយពីគ្រីស្ទាននឹងជ្រាបចូលក្នុងក្រុមជំនុំគ្រីស្ទានបន្តិចម្ដងៗ ។ ពួកមនុស្សនឹងទាញយកអ្នកមានជំនឿឲ្យតាមខ្លួនគេជាជាងតាមព្រះគ្រីស្ទ ។ (ម៉ាថាយ ៧:១៥, ២១-២៣; កិច្ចការ ២០:២៩, ៣០) ហេតុនេះហើយបានជាយើងឃើញមានសាសនាខុសៗគ្នាយ៉ាងច្រើនដូច្នេះ ដែលអះអាងថាជាសាសនាគ្រីស្ទាន ។ តើយើងអាចសម្គាល់គ្រីស្ទានពិតយ៉ាងដូចម្ដេច ?

៣. កំណត់សម្គាល់ដ៏ល្អបំផុតរបស់គ្រីស្ទានពិត គឺថាពួកគេមានសេចក្ដីស្រឡាញ់ស្មោះនឹងគ្នា ។ (យ៉ូហាន ១៣:៣៤, ៣៥) ពួកគេឥតបានត្រូវបង្រៀនឲ្យគិតថា ខ្លួនគេគឺល្អប្រសើរជាងមនុស្សខាងពូជសាសន៍ឬពណ៌សម្បុរដទៃឡើយ ហើយក៏ឥតបានត្រូវបង្រៀនឲ្យស្អប់មនុស្សពីប្រទេសផ្សេងៗដែរ ។ (កិច្ចការ ១០:៣៤, ៣៥) ដូច្នេះ ពួកគេមិនចូលរួមក្នុងសង្គ្រាមទេ ។ គ្រីស្ទានពិតរាប់រកគ្នាទៅវិញទៅមកទុកដូចជាបងប្អូនប្រុសស្រី ។—យ៉ូហានទី១ ៤:២០, ២១

៤. កំណត់សម្គាល់មួយទៀតរបស់សាសនាគ្រីស្ទានពិតគឺថាសមាជិកគេមានសេចក្ដីគោរពដ៏ជ្រាលជ្រៅចំពោះព្រះគម្ពីរ ។ ពួកគេទទួលស្គាល់ព្រះគម្ពីរថាជាបន្ទូលនៃព្រះ ហើយជឿតាមអ្វីៗដែលព្រះគម្ពីរថែងប្រាប់ ។ (យ៉ូហាន ១៧:១៧; ធីម៉ូថេទី២ ៣:១៦, ១៧) ពួកគេចាត់ទុកថាបន្ទូលព្រះគឺសំខាន់ជាងគំនិតឬទំនៀមទម្លាប់របស់មនុស្ស ។ (ម៉ាថាយ ១៥:១-៣, ៧-៩) ពួកគេខំរស់នៅតាមសេចក្ដីបង្រៀនពីព្រះគម្ពីរជានិច្ចក្នុងជីវភាពប្រចាំថ្ងៃរបស់គេ ។ ដូច្នេះ ពួកគេមិនផ្សាយប្រកាសអំពីអ្វីមួយ ហើយប្រព្រឹត្តផ្ទុយទៅវិញនោះឡើយ ។—ទីតុស ១:១៥, ១៦

៥. សាសនាពិតត្រូវតែលើកដំកើងព្រះនាមនៃព្រះ ។ (ម៉ាថាយ ៦:៩) ព្រះយេស៊ូមានបន្ទូលប្រាប់ព្រះនាមនៃព្រះ គឺយេហូវ៉ា ឲ្យមនុស្សឯទៀតស្គាល់ ។ ឯគ្រីស្ទានពិតក៏ត្រូវតែធ្វើដូច្នេះដែរ ។ (យ៉ូហាន ១៧:៦, ២៦; រ៉ូម ១០:១៣, ១៤) តើពួកណាក្នុងសហគមន៍អ្នក ដែលថ្លែងប្រាប់អ្នកឯទៀតអំពីព្រះនាមនៃព្រះ ?

៦. គ្រីស្ទានពិតត្រូវតែផ្សាយប្រកាសអំពីព្រះរាជាណាចក្រនៃព្រះ ។ ព្រះយេស៊ូទ្រង់បានធ្វើកិច្ចការនេះ គឺទ្រង់តែងមានបន្ទូលប្រាប់អំពីព្រះរាជាណាចក្រ ។ (លូកា ៨:១) ទ្រង់បញ្ជាពួកសិស្សរបស់ទ្រង់ឲ្យផ្សាយប្រកាសដំណឹងដូចគ្នានេះពាសពេញលើផែនដីទាំងមូល ។ (ម៉ាថាយ ២៤:១៤; ២៨:១៩, ២០) គ្រីស្ទានពិតជឿថាមានតែព្រះរាជាណាចក្រនៃព្រះទេ ដែលនឹងនាំមកនូវសន្តិភាពនិងសន្តិសុខពិតប្រាកដលើផែនដីនេះបាន ។ —ទំនុកដំកើង ១៤៦:៣-៥

៧. ពួកសិស្សរបស់ព្រះយេស៊ូត្រូវតែកុំចូលរួមចំណែកនឹងលោកីយ៍ដ៏អាក្រក់នេះ ។ (យ៉ូហាន ១៧:១៦) ពួកគេមិនចូលទាក់ទងក្នុងកិច្ចការនយោបាយនិងរឿងជម្លោះខាងសង្គមរបស់លោកីយ៍នេះឡើយ ។ ពួកគេជៀសវាងគំនិតមារយាទ ការប្រព្រឹត្ត និងអាកប្បកិរិយាដែលនាំឲ្យមានទុក្ខទោស ដែលជារបស់ធម្មតាទូទៅក្នុងលោកីយ៍ ។ (យ៉ាកុប ១:២៧; ៤:៤) តើអ្នកអាចសម្គាល់ក្រុមសាសនាមួយក្នុងសហគមន៍របស់អ្នកឬទេ ដែលមានកំណត់សម្គាល់ទាំងនេះនៃសាសនាគ្រីស្ទានពិតនោះ ?





*គ្រីស្ទានពិត ស្រឡាញ់គ្នាទៅវិញទៅមក គោរពតាមព្រះគម្ពីរ ហើយផ្សាយប្រកាសអំពីព្រះរាជាណាចក្រនៃព្រះ*